**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០២៨ សហវ.អគពដ.

# សេចក្តីជូនដំណឹង

## ស្តីពី

## ចំណុចសំខាន់ៗនៃច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ

អនុលោមតាមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ (ចសព) ដែល ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម ០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៣ និងក្នុងគោលដៅអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិទាំងឡាយឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយសសូមជំរាបជូននូវចំណុចសំខាន់ៗនៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ (ចវចសព) និងបទប្បញ្ញត្តិពាក់ព័ន្ធ ដូចខាងក្រោម:

### ១. ពន្ធលើប្រាក់ចំណេញ

#### ក- រំលស់ទ្រព្យរូបី (មាត្រា ១៣ថ្មី)

មានការកែប្រែថ្មីអំពី វិធីរំលស់ ចំណាត់ថ្នាក់ទ្រព្យ អត្រារំលស់ និងការដាក់ឱ្យប្រើនូវរំលស់ពិសេស ។

អ្នកជាប់ពន្ធ និងអ្នកជួលដែលទទួលខុសត្រូវលើហានិភ័យ ត្រូវបានអនុញ្ញាតឱ្យប្រើវិធីរំលស់ទ្រព្យរូបីពីរវិធីគឺ: វិធីរំលស់ស្មើភាគសំរាប់ថ្នាក់១ និង វិធីរំលស់ថយជាលំដាប់សំរាប់ ថ្នាក់២ ថ្នាក់៣ និង ថ្នាក់៤ ។

ចំណាត់ថ្នាក់ទ្រព្យរូបីមានដូចតទៅ :

- ថ្នាក់១រួមមាន អគារ រចនាសម្ព័ន្ធរបស់អគារ និង សំណង់ដែលជាសមាសភាគនៃអគារនោះ ត្រូវធ្វើរំលស់តាមវិធីរំលស់ស្មើភាគ តាមអត្រា ៥% ក្នុងមួយឆ្នាំនៃបរិយាទានលទ្ធកម្ម (ថ្លៃដើម) ។
- ថ្នាក់២រួមមាន កុំព្យូទ័រ ប្រព័ន្ធព័ត៌មានអេឡិចត្រូនិច សហ្វវែរ និងបរិក្ខារទុកដាក់ទិន្នន័យ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់ តាមអត្រា ៥០% នៃមូលដ្ឋានរំលស់នៅក្នុងមួយឆ្នាំ ។
- ថ្នាក់៣រួមមាន រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់ តាមអត្រា ២៥% នៃមូលដ្ឋានរំលស់នៅក្នុងមួយឆ្នាំ ។
- ថ្នាក់៤រួមមាន រាល់គ្រប់ប្រភេទនៃទ្រព្យសកម្មរូបីដទៃផ្សេងៗទៀត ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់ តាមអត្រា ២០% នៃមូលដ្ឋានរំលស់នៅក្នុងមួយឆ្នាំ ។

ការអនុញ្ញាតនូវរំលស់ពិសេសតាមអត្រា ៤០% ចំពោះទ្រព្យថ្មីឬទ្រព្យប្រើប្រាស់រួច សំរាប់ផលិតកម្ម និងដំណើរការកែច្នៃ ប្រសិនបើគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គលគ) មិនជ្រើសរើសរយៈពេលលើកលែងពន្ធ ក្រោមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

បទប្បញ្ញត្តិស្តីពីរំលស់ទ្រព្យរូបីដូចខាងលើនេះ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៤ តទៅ ។

## ខ- អាត្រាពន្ធលើប្រាក់ចំណេញ (មាត្រា ២០ថ្មី)

អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំមានដូចតទៅ :

- ២០% ចំពោះនីតិបុគ្គល, ៣០% ចំពោះអាជីវកម្មប្រេងកាតនិងឧស្ម័នធម្មជាតិ ឬធនធានធម្មជាតិ
- ៩% ចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់(គលគ) ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (កអក) សម្រាប់រយៈពេលអន្តរកាល ៥ឆ្នាំ (កែប្រែថ្មី)
- ០% ចំពោះ គលគ ដែលស្ថិតក្នុងរយៈ ពេលលើកលែងពន្ធ ដែលកំណត់ដោយ កអក (កែប្រែថ្មី)
- ០% ដល់ ២០% តាមអត្រាកំណើនតាមថ្នាក់ ចំពោះរូបវន្តបុគ្គល និង សមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្ម
- ៥% នៃបុព្វលាភដុលដែលទទួលបានក្នុងឆ្នាំ ចំពោះការធានារ៉ាប់រង ឬការធានារ៉ាប់រងបន្តនូវហានិភ័យកម្ពុជា។

ការកែប្រែបទប្បញ្ញត្តិដូចខាងលើនេះ ចាប់ផ្តើមអនុវត្ត ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៤ តទៅ ។

## គ- ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ (មាត្រា ២៣ថ្មី)

ពន្ធលើការបែងចែកភាគលាភ ត្រូវបានកែប្រែទៅជាពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងត្រូវបានកំណត់ដូចខាងក្រោមនេះ :

- ២០% ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ប្រសិនបើសហគ្រាសបានបង់ពន្ធប្រាក់ចំណេញតាមអត្រា០% រួចហើយ, និងចំពោះការបែងចែកដទៃទៀតក្នុងឆ្នាំជាប់ពន្ធ ។
- ១១ ភាគ ៨១ ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ប្រសិនបើសហគ្រាសបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% រួចហើយ ។
- ០% ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ប្រសិនបើសហគ្រាសបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០% រួចហើយ ។

សហគ្រាសដែលទទួលភាគលាភបានបង់ពន្ធរួចដូចខាងលើ ត្រូវកត់ត្រាប្រាក់ភាគលាភនោះក្នុងគណនីភាគលាភរបស់ខ្លួន។ ពេលបែងចែកភាគលាភជាបន្ត មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញបន្ថែមដូចខាងលើនេះទៀតឡើយ ។

កាលបរិច្ឆេទចាប់ផ្តើមអនុវត្តពន្ធនេះ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៤ តទៅ ។

## ឃ- ពន្ធអប្បបរមា និងប្រាក់រំដោះនៃពន្ធលើប្រាក់ចំណេញ (មាត្រា ២៤ថ្មី និងមាត្រា ២៨ថ្មី)

ការកែប្រែថ្មី គឺពន្ធអប្បរមា និងប្រាក់រំដោះពន្ធលើប្រាក់ចំណេញ មិនត្រូវបង់ដោយ គលគ ទេ ។ អាករលើតម្លៃបន្ថែម (VAT) ក៏មិនបញ្ចូលក្នុងផលរបរដែលជាមូលដ្ឋានគិតពន្ធទាំងនេះដែរ ។

ពន្ធអប្បបរមា និងប្រាក់រំដោះពន្ធលើប្រាក់ចំណេញត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបពិត ប៉ុន្តែពន្ធអប្បបរមាមិនត្រូវបង់ដោយ គលក ទេ និងប្រាក់រំដោះពន្ធលើប្រាក់ចំណេញក៏មិនត្រូវបង់ដែរដោយ គលក ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ ។ ចំពោះពន្ធអប្បបរមាត្រូវបង់តាមអត្រា ១% លើផលរបរប្រចាំឆ្នាំ និងចំពោះប្រាក់រំដោះពន្ធលើប្រាក់ចំណេញ តាមអត្រា ១% លើផលរបរប្រចាំខែ ដោយរួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ។

គលក ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% ក៏មានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធនេះដែរ ។

ការកែប្រែបទប្បញ្ញត្តិនៃពន្ធទាំងពីរខាងលើនេះ ចាប់ផ្តើមអនុវត្ត ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៤ តទៅ ។

## ង- ពន្ធកាត់ទុកទូទៅចំពោះអ្នកជាប់ពន្ធនិវាសនជន (មាត្រា ២៥ថ្មី)

និយមន័យនៃពាក្យ "អ្នកបើកប្រាក់និវាសនជន" ក្នុងកថាខ័ណ្ឌ ៣ ត្រូវលុបចោលហើយជំនួសដោយពាក្យ "អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម" ក្នុងកថាខ័ណ្ឌ១ វិញ ។ លុបពាក្យ "ប្រេងកាតឬឧស្ម័នធម្មជាតិ" ក្នុងចំណុច ២ កថាខ័ណ្ឌ ក ។ ដូច្នេះ ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចខាងក្រោម :

១- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ ឱ្យដល់អ្នកជាប់ពន្ធនិវាសនជន ត្រូវកាត់ទុក និង បង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ:

ក. អត្រា ១៥ ភាគរយ ចំពោះ :

- ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបី និង ភាគកម្មក្នុងធនធានរ៉ែ
- ការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន

ខ. អត្រា ១០ ភាគរយ ចំពោះប្រាក់ចំណូលពីការឱ្យជួលចលន ឬអចលនទ្រព្យ

គ. អត្រា ៦ ភាគរយ ចំពោះការប្រាក់ដែលធនាគារឬស្ថាប័នសញ្ជ័យធនក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់ (ចសព អត្រា ១៥%)

ឃ. អត្រា ៤ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីសន្សំគ្មានកាលកំណត់ (ចសព អត្រា ៥%)

២- ការកាត់ទុកក្នុងមាត្រានេះ មិនត្រូវអនុវត្តទេចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារ និងស្ថាប័នសញ្ជ័យធនក្នុងស្រុក និង ការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា ៩ ថ្មី នៃ ចវសព ។

- ចំណុចកែប្រែថ្មី: ពន្ធកាត់ទុកនេះក៏មិនត្រូវអនុវត្តទេចំពោះប្រាក់ចំណូលរបស់សហគ្រាសជាប់ពន្ធតាមរបបពិតដែលបំពេញ សេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល ។

៣- ចំណុចកែប្រែថ្មី: ពន្ធកាត់ទុកត្រូវអនុវត្តចំពោះការទូទាត់ (ការប្រាក់ សួយសារ ថ្លៃឈ្នួល....) រវាងសហគ្រាសជាប់ពន្ធតាមរបបពិត និងសហគ្រាសជាប់ពន្ធតាមរបបពិតដូចគ្នា (លើកលែងតែកថាខ័ណ្ឌ ២ ខាងលើនេះ) ។

កាលបរិច្ឆេទចាប់ផ្តើមអនុវត្តការកែប្រែពន្ធកាត់ទុកទូទៅនេះ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០០៤ តទៅ។

### ច- ពន្ធកាត់ទុកលើការទូទាត់ប្រាក់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជន (មាត្រា ២៦ថ្មី)

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានទូទាត់ប្រាក់ចំណូលខាងក្រោមនេះ ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធចំនួន ១៤% (ចសព អត្រា ១៥%) នៃទឹកប្រាក់ត្រូវបើក:

ក. ការប្រាក់

ខ. សួយសារ ថ្លៃឈ្នួល និង ប្រាក់ចំណូលផ្សេងៗទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ

គ. ការទូទាត់ចំពោះសេវាគ្រប់គ្រង និង សេវាបច្ចេកទេសនានា

ឃ. ភាគលាភ ។

កាលបរិច្ឆេទចាប់ផ្តើមអនុវត្តការកែប្រែពន្ធកាត់ទុកនេះ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៤ តទៅ ។

## ២. ពន្ធលើប្រាក់បៀវត្សរ៍របស់អ្នកជាប់ពន្ធអនិវាសនជន (មាត្រា ៤៩ថ្មី)

ចំពោះអ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឱ្យតាមអត្រា ២០% (ចសព អត្រា ១៥%) លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធ ។

កាលបរិច្ឆេទចាប់ផ្តើមអនុវត្តការកែប្រែពន្ធកាត់ទុកនេះ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៤ តទៅ ។

## ៣. វិធាននិងនីតិវិធីសារពើពន្ធ

### ក- ការផ្តល់ពត៌មានដល់អ្នកជាប់ពន្ធ (មាត្រា ៩៥ថ្មី)

១. លិខិតស្នាម ឬលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ លុះណាតែរដ្ឋបាលសារពើពន្ធ:

- ផ្ញើជាលាយលក្ខណ៍អក្សរ និងបានប្រគល់ឱ្យបុគ្គលនោះ ឬក៏បានផ្ញើតាមប្រៃសណីយ៍ ដោយភ្ជាប់កាលបរិច្ឆេទបោះត្រាលើលិខិតអនុសិដ្ឋរបស់ការិយាល័យប្រៃសណីយ៍នោះ ទោះបីជាបុគ្គលដែលត្រូវបានជូនដំណឹងនោះបដិសេធការប្រគល់ ឬការទទួលលិខិតអនុសិដ្ឋក្តី
- បានបញ្ជូនទៅអាស័យដ្ឋានដែលបានស្គាល់ចុងក្រោយបង្អស់ ក្នុងករណីដែលអាស័យដ្ឋានរបស់បុគ្គលត្រូវបានផ្លាស់ប្តូរ ហើយបុគ្គលមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធ អំពីការផ្លាស់ប្តូរនោះទេ ។

២. ចំណុចបន្ថែមថ្មី : ក្នុងករណីដោយមូលហេតុណាមួយដែលលិខិតស្នាម ឬលិខិតជូនដំណឹងមិនអាចផ្តល់ដល់អ្នកជាប់ពន្ធដូចមានចែងក្នុងកថាខ័ណ្ឌ ១ ខាងលើ លិខិតស្នាម ឬលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ ប្រសិនបើរដ្ឋបាលសារពើពន្ធបាន:

ក. បិទលិខិតស្នាម ឬលិខិតជូនដំណឹងភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋាន ឬទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ឬ

ខ. ផ្សព្វផ្សាយតាមសារពត៌មាន ដោយតម្រូវឱ្យអ្នកជាប់ពន្ធចូលមករដ្ឋបាលសារពើពន្ធ មិនឱ្យលើសពី ១៤ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ ។

កាលបរិច្ឆេទចាប់ផ្តើមអនុវត្តការកែប្រែបទប្បញ្ញត្តិនេះ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៤ តទៅ ។

**ខ- ការរៀបចំ និងដាក់លិខិតប្រកាសសារពើពន្ធ (មាត្រា ១០៤ថ្មី)**

១- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ ពេលវេលា និង ទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។

២- លិខិតប្រកាសសារពើពន្ធ ត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធ ឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ ។

៣- ចំណុចបន្ថែមថ្មី: អ្នកវិនិយោគទាំងអស់ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ សម្រាប់ខែនីមួយៗ និង លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ និងបង់ពន្ធអាករទាំងអស់ទៅតាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ ។

៤- ចំណុចបន្ថែមថ្មី: អ្នកវិនិយោគទាំងអស់ ត្រូវភ្ជាប់នូវវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បញ្ជាក់ពីការគោរពប្រតិបត្តិជាមួយលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធនោះ ។

កាលបរិច្ឆេទចាប់ផ្តើមអនុវត្តការកែប្រែបទប្បញ្ញត្តិនេះ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៤ តទៅ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា អ្នកជាប់ពន្ធទាំងអស់នឹងការសហការ អនុវត្តតាមសេចក្តីជូនដំណឹងនេះបានត្រឹមត្រូវ និងមានប្រសិទ្ធិភាព ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៣

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

*កន្លែងទទួល:*

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ